As a contractor you are keenly aware of the accidents that could happen during construction such as fire, flood, the collapse of surrounding properties and accident to your workers.

Campu Lonpac Contractor's/Erection All Risks Insurance and Workers' Accident Insurance cover accidents during your project period.

Our policy covers most of the major aspects of your constructions. As an insurer with a comprehensive range of products, we can assist you to tailor make an insurance cover which suits the nature of your construction.

## *What Insurance should I purchase to cover my project?*

**Contractor's All Risks (CAR) Insurance**
CAR Insurance is taken up when your project works mainly involves civil and structural works including renovation works.

**Erection All Risks (EAR) Insurance**
EAR Insurance is taken up when your project mainly involves erection and installations of plant and machineries.

Both CAR and EAR Insurances cover damage to your contract works including theft of your construction materials.

It also covers your legal liability to compensate third parties when your construction works caused property damage and injury to such third parties.

**Workers' Accident Insurance**
This insurance covers accidents of your workers during the construction period. The policy will pay a lump sum benefit in the event of death or permanent disablement and reimburse you the medical expenses incurred due to accident.

## *Who can buy Project Insurance?*

- The Owner of the project
- The Main Contractor
- The Sub-Contractors
- The manufacturer or supplier of the machinery or plant if they carry out the erection work or is responsible for it

## *How much should I insure?*

For Contractor's or Erection All Risks Insurance, you should insure the full contract value of the project.

On the third party liability cover, the limit in the policy will be the amount required by the owner of the project or based on your project's potential liability exposure.

## *How long is the period of insurance?*

The policy will cover the whole project duration up to hand over date plus the defects liability period.

Note: For specific terms and conditions, please refer to our policy wording.

BR-E-1211/v2.0

ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី
CAMPU LONPAC INSURANCE PLC.

7th Floor, Campu Bank Building
No. 23, Street 114, Sangkat Phsar Thmey II, Khan Daun Penh
Phnom Penh, Royal Kingdom of Cambodia.
P.O Box 1556

Tel: +855 23 966 966 | Fax: + 855 23 986 273
24 Hours Claims Hotline: 016 810 999/ 017 799 903
E-mail: enquiries@campulonpac.com.kh
Website: www.campulonpac.com.kh

ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE

# កិច្ចសន្យាធានារ៉ាប់រងលើគំរោងនានា

# Project Insurance




ក្នុងនាមជាអ្នកម៉ៅការសំណង់លោកអ្នកត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគ្រោះថ្នាក់មួយចំនួនដែលអាចកើតឡើងកំឡុងពេលសាងសង់ដូចជា អគ្គិភ័យ ទឹកជំនន់ ការដួលរលំនៃអចលនទ្រព្យដែលនៅជុំវិញការដ្ឋានសំណង់ និងគ្រោះថ្នាក់មួយចំនួនផ្សេងទៀតដែលអាចកើតមានឡើងចំពោះកម្មករនិយោជិត ។

កិច្ចសន្យាធានារ៉ាប់រងលើការសាងសង់ ឬហានិភ័យនៃសំណង់ និងកិច្ចសន្យាធានារ៉ាប់រងលើគ្រោះថ្នាក់ការងារចំពោះកម្មករ និយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក នឹងរ៉ាប់រងលើគ្រោះថ្នាក់ ឬឧប្បត្តិហេតុទាំងឡាយ ដែលអាចកើតមានឡើងដោយចៃដន្យនៅក្នុងការអនុវត្តគំរោងរបស់លោកអ្នក។

កិច្ចសន្យានេះនឹងធានារ៉ាប់រងលើផ្នែកភាគច្រើននៃគំរោងសាងសង់របស់លោកអ្នក ។ ក្នុងនាមជាអ្នកផ្តល់សេវាកម្មធានារ៉ាប់រងទូទៅយើងខ្ញុំអាចជួយលោកអ្នកក្នុងការជ្រើសរើសការធានារ៉ាប់រងដែលសមស្របទៅនឹងស្ថានភាពសំណង់របស់លោកអ្នក ។

## តើកិច្ចសន្យាធានារ៉ាប់រងមួយណា ដែលខ្ញុំគួរជ្រើសរើសយកដើម្បីការពារគំរោងសាងសង់របស់ខ្ញុំ?

**កិច្ចសន្យាធានារ៉ាប់រងលើហានិភ័យសំរាប់អ្នកមៅការសំណង់ (CAR)**
កិច្ចសន្យាធានារ៉ាប់រង **CAR** គួរត្រូវបានជ្រើសរើសនៅពេលគំរោងការរបស់លោកអ្នកទាក់ទងផ្នែកសំណង់ស៊ីវិលរួមទាំងការងារទាក់ទងនឹងការជួសជុលលំអរអគារជាដើម ។

**កិច្ចសន្យាធានារ៉ាប់រងលើហានិភ័យក្នុងពេលសាងសង់ (ទាក់ទងនឹងការងារជាក់ស្តែងដូចជាការតម្លើង ការសាងសង់ ការធ្វើតេស្តសាកល្បងលើគ្រឿងចក្រ ឬម៉ាស៊ីនធានា EAR )**
កិច្ចសន្យាធានារ៉ាប់រង **EAR** គួរត្រូវបានជ្រើសរើសនៅពេលគំរោងលោកអ្នកទាក់ទងនឹងការសាងសង់ និងការតម្លើងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនធានា ។

កិច្ចសន្យាធានារ៉ាប់រងទាំងពីរ **CAR** និង **EAR** គ្របដណ្តប់រាល់ការខូចខាតទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចសន្យាការងាររបស់លោកអ្នក រួមទាំងការបាត់បង់សំភារៈសំណង់ ដែលបណ្តាលមកពីអំពើចោរកម្ម ។

កិច្ចសន្យាធានារ៉ាប់រងខាងលើ ក៏ទទួលខុសត្រូវផងដែរលើសំណងរដ្ឋប្បវេណីស្របច្បាប់របស់លោកអ្នក ចំពោះភាគីតតិយជននៅពេលដែលការងារសាងសង់របស់លោកអ្នកអាចបង្កការខូចខាតដល់ទ្រព្យសម្បត្តិ និងរបួសស្នាមដល់ភាគីតតិយជន ។

**កិច្ចសន្យាធានារ៉ាប់រងគ្រោះថ្នាក់ការងារ ចំពោះកម្មករនិយោជិត**
កិច្ចសន្យាធានារ៉ាប់រងនេះនឹងរ៉ាប់រងលើគ្រោះថ្នាក់ទាំងឡាយណាដែលកើតឡើងចំពោះកម្មករនិយោជិតក្នុងពេលកំពុងសាងសង់ ។ កិច្ចសន្យាធានារ៉ាប់រងនេះនឹងធ្វើសំណងក្នុងករណីបាត់បង់ជីវិត ឬពិការភាពជាអចិន្ត្រៃយ៍ និងចេញថ្លៃព្យាបាលរបួសដែលកើតឡើងដោយសារគ្រោះថ្នាក់ដោយចៃដន្យ ។

## តើអ្នកណាខ្លះអាចទិញធានារ៉ាប់រងលើគំរោងនេះបាន?

- ម្ចាស់គំរោង
- អ្នកម៉ៅការសំណង់
- អ្នកម៉ៅការបន្ត
- អ្នកផលិត ឬក៏អ្នកផ្គត់ផ្គង់ផ្នែកគ្រឿងម៉ាស៊ីន ឬគ្រឿងចក្រប្រសិនបើពួកគេជាអ្នកអនុវត្តការងារសាងសង់ ឬជាអ្នកដែលទទួលខុសត្រូវលើគំរោងសាងសង់ ។

## តើគំរោងរបស់ខ្ញុំគួរតែធានាក្នុងតំលៃប៉ុន្មាន?

សំរាប់កិច្ចសន្យាធានារ៉ាប់រង **CAR** និង **EAR** លោកអ្នកគួរតែធានាលើតំលៃគំរោងទាំងមូល ។ សំរាប់ការទទួលខុសត្រូវចំពោះភាគីតតិយជនវិញ តំលៃដែលត្រូវធានាក្នុងកិច្ចសន្យានឹងត្រូវកំណត់ដោយម្ចាស់គំរោង ឬក៏អាស្រ័យលើសក្តានុពលនៃការទទួលខុសត្រូវរបស់គំរោងលោកអ្នក ។

## តើកិច្ចសន្យាធានារ៉ាប់រងនេះមានរយៈពេលប៉ុន្មាន?

កិច្ចសន្យាធានារ៉ាប់រងនេះមានរយៈពេលពេញមួយគំរោងតែម្តងគឺ ចាប់ផ្តើមពីថ្ងៃសាងសង់ដំបូង រហូតដល់ថ្ងៃបញ្ចប់គំរោងបូករួមទាំងរយៈពេលទទួលខុសត្រូវលើអនិបុណភាព ។

កំណត់សំគាល់ៈ រាល់ ខ ចែង និងលក្ខខណ្ឌជាក់លាក់ទាំងអស់ត្រូវយោងទៅលើអត្ថន័យដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងរបស់យើងខ្ញុំ ។

ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី
CAMPU LONPAC INSURANCE PLC.

ជាន់ទី៧ នៃអគារកម្ពុប៊ែង
ផ្ទះលេខ ២៣ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មី ២ ខ័ណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១៥៥៦

ទូរស័ព្ទ: +៨៥៥ ២៣ ៩៦៦ ៩៦៦ | ទូរសារ: +៨៥៥ ២៣ ៩៨៦ ២៧៣
លេខទូរស័ព្ទប្រចាំការ២៤ម៉ោង: ០១៦ ៨១០ ៩៩៩/ ០១៧ ៧៩៩ ៩០៣
អ៊ីមែល: enquiries@campulonpac.com.kh
គេហទំព័រ: www.campulonpac.com.kh